# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦

## ពិធីប្រគល់លិខិតសរសើរពីរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុនជូនចំពោះ លោកកូជិ តេហ្សឹកា លោកស្រីឡុច លក្ខស្មី និងលោកកេនជិ កូយ៉ាម៉ា

ពិធីប្រគល់លិខិតសរសើរ ពីរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ជូនចំពោះលោក កូជិ តេហ្សឹកា ជាទីប្រឹក្សាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត និងលោកស្រីឡុច ល័ក្ខស្មីប្រធានដេប៉ាតឺម៉ង់ភាសាជប៉ុននៃវិទ្យាស្ថានភាសាបរទេស នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានប្រព្រឹត្តិទៅនៅថ្ងៃទី២៦ ខែសីហា នៅនិវេសនដ្ឋានឯកឧត្តមឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា។

នៅក្នុងឱកាសនេះ លោកកេនជិកូយ៉ាម៉ា ជាចុងភៅផ្ទាល់របស់ឯកឧត្តមឯកអគ្គរាជទូត ក៏បានទទួលលិខិតសរសើរពីលោករដ្ឋមន្ត្រីការបរទេសដែរ សម្រាប់ការវាយតម្លៃជាចុងភៅដ៏ចំណានបំផុតសម្រាប់ឯកអគ្គរាជទូត ឬក៏ឯកអគ្គកុងស៊ុលជប៉ុន។

នៅថ្ងៃទី១៣ ខែកក្កដា រដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុនបានប្រកាសនូវការប្រគល់លិខិតសរសើរសម្រាប់ឆ្នាំនេះ ជូនចំពោះបុគ្គល ឬក្រុមដែលស្នាដៃឆ្នើមក្នុងវិស័យអន្តរជាតិ ដើម្បីទទួលស្គាល់ការរួមចំណែករបស់ពួកគេ ក្នុងការជម្រុញនូវមិត្តភាពរវាងជប៉ុន និងកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត។

លោក **កូជិ តេហ្សឹកា** ទីប្រឹក្សាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតបានរួមចំណែកជម្រុញនូវការយល់ដឹងពីគ្នាទៅវិញទៅមកតាមរយៈសកម្មភាពនានារបស់លោកអស់រយៈពេល៣២ ឆ្នាំ ដែលរួមមានការបម្រើការជាបុគ្គលិកអង្គការដើម្បីជួយដល់ជនភាសខ្លួនកម្ពុជា និងលើកស្ទួយការអប់រំនៅកម្ពុជា និងធ្វើជាប្រធានសមាគមជប៉ុនចំនួនបីដង។

ចំពោះលោកស្រី **ឡុច ល័ក្ខស្មី** ប្រធានដេប៉ាតឺម៉ង់ភាសាជប៉ុន នៃវិទ្យាស្ថានភាសា

បរទេស សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានរួមចំណែកជម្រុញការសិក្សាភាសាជប៉ុននៅប្រទេសកម្ពុជា។

លោក **កេនជិ គូយ៉ាម៉ា** បានផ្សព្វផ្សាយម្ហូបជប៉ុននៅកម្ពុជា ដែលក្នុងនោះមិនត្រឹមតែនៅនិវេសនដ្ឋានឯកឧត្តមឯកអគ្គរាជទូតតែប៉ុណ្ណោះទេ ប៉ុន្តែលោកក៏បានផ្សព្វផ្សាយនៅក្នុងព្រឹត្តិការណ៍វប្បធម៌នានា និងក្នុងកម្មវិធីទូរទស្សន៍ផងដែរ។